# ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់គង់ក្នុងខ្ញុំ

នៅពេលដែលខ្ញុំចាប់ផ្ដើមទទួលជឿលើព្រះយេស៊ូវគ្រីស្ទ នោះទ្រង់ក៏ដៅចំណាំខ្ញុំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ។(១)

ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់រស់ក្នុងខ្ញុំ (២)
ហើយនឹងគង់ជាមួយខ្ញុំ ជារៀងរហូត (៣)
ទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្ដិ៍អាកររបស់ខ្ញុំ
ជាមួយនឹងព្រះជាម្ចាស់ ។(៤)

ព្រះវិញ្ញាណបរិសុទ្ធ បានប្រទាននូវអំណាចមកខ្ញុំ ដើម្បីឱ្យខ្ញុំធ្វើបន្ទាល់ពីទ្រង់។(៥) ហើយដោយសារទ្រង់ ខ្ញុំអាចផ្សាយព្រះបន្ទូលទ្រង់ដោយចិត្តក្លាហាន។ (៦)

ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ដឹកនាំខ្ញុំចូលក្នុងគ្រប់ទាំងសេចក្ដីពិត។ (៧)

ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ក៏ជួយសេចក្ដីកំសោយរបស់ខ្ញុំ ហើយទ្រង់ជួយអង្វរជួសខ្ញុំ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ។ (៨)

ហើយដោយសារទ្រង់ ខ្ញុំបានប្រើសេចក្ដីអធិស្ឋាន និងសេចក្ដីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា។ (៩)

ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់នឹងដំកើងព្រះយេស៊ូវនៅក្នុងខ្ញុំ ។(១០)

ហើយដោយសារសេចក្ដីស្រឡាញ់របស់ព្រះ នោះបានផ្សាយមកសព្វក្នុងចិត្តរបស់ខ្ញុំ។ (១១)

## អាម៉ែន!

(១) អេភេសូរ ១:១៣-១៤
(២) ១កូរិនថូស ៦:១៩
(៣) យ៉ូហាន ១៤:១៦
(៤) អេភេសូរ ១:១៣ខ-១៤
(៥) កិច្ចការ ១:៨
(៦) កិច្ចការ ៤:៣១
(៧) ២កូរិនថូស ៣:៦ & យ៉ូហាន ១៦:១៣-១៤
(៨) រ៉ូម ៨:២៦-២៧
(៩) អេភេសូរ ៦:១៨
(១០) យ៉ូហាន ១៦:១៤
(១១) រ៉ូម ៥:៥

**អេភេសូរ ១: ១៣-១៤** ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្ដីពិត គឺជាដំណឹងល្អពីសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ១៤ ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្ដិ៍អាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សំរាប់ជាសេចក្ដីសរសើរដល់សិរីល្អនៃទ្រង់។

**១កូរិនថូស ៦: ១៩** តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ។

**យ៉ូហាន ១៤: ១៦** នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ ១អង្គទៀត មកអ្នករាល់គ្នា ឲ្យបានគង់នៅជាមួយ នៅអស់កល្បរៀងទៅ ។

**អេភេសូរ ១: ១៣ខ-១៤** ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ១៤ ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្ដិ៍អាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សំរាប់ជាសេចក្ដីសរសើរដល់សិរីល្អនៃទ្រង់។

**កិច្ចការ ១: ៨** ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្ដា ហើយនិងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង។

**កិច្ចការ ៤: ៣១** កាលបានអធិស្ឋានរួចហើយ នោះកន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ ហើយគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា រួចក៏ផ្សាយព្រះបន្ទូលដោយចិត្តក្លាហាន។

**២កូរិនថូស ៣: ៦** ដែលទ្រង់បានប្រោស ឲ្យយើងខ្ញុំអាចនឹងធ្វើជាអ្នក
បំរើនៃសញ្ញាថ្មីបាន មិនមែនតាមតែន័យពាក្យប៉ុណ្ណោះទេ គឺតាមព្រះវិញ្ញាណវិញ ដ្បិតន័យពាក្យ នោះធ្វើឲ្យស្លាប់ តែព្រះវិញ្ញាណ ទ្រង់ប្រទានឲ្យមានជីវិតវិញ។

**យ៉ូហាន១៦: ១៣-១៤** កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្ដីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំង សេចក្ដីពិត ដ្បិតទ្រង់នឹងមានព្រះបន្ទូលមិនមែនដោយអាងព្រះអង្គទ្រង់ទេ គឺនឹងមានព្រះបន្ទូល ចំពោះតែសេចក្ដីណាដែលទ្រង់ឮ ហើយនិងសំដែង ឲ្យអ្នករាល់គ្នាដឹងការដែលត្រូវមក ១៤ ទ្រង់នឹងដំកើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្ដីដែលតម្រូវពីខ្ញុំ មកប្រាប់ដល់អ្នករាល់គ្នា ។

**រ៉ូម ៨: ២៦-២៧** ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្ដីកំសោយរបស់យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានវិញ ២៧ ប៉ុន្តែ ព្រះអង្គដែលស្ទង់ចិត្ត ទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ។

**អេភេសូរ ៦: ១៨** ព្រមទាំងប្រើសេចក្ដីអធិស្ឋាន និងសេចក្ដីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងសេចក្ដីនោះឯង ដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន និងសេចក្ដីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់។

**យ៉ូហាន ១៦: ១៤** ទ្រង់នឹងដំកើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្ដីដែលតម្រូវពីខ្ញុំ មកប្រាប់ដល់អ្នករាល់គ្នា ។

**រ៉ូម ៥: ៥** ឯសេចក្ដីសង្ឃឹមក៏មិនដែលនាំឲ្យយើងមានសេចក្ដីខ្មាសឡើយ ពីព្រោះសេចក្ដីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើងហើយ ។


**បកប្រែដោយ: ONE -2- ONE CAMBODIA**

**អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**

**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

www.One-2-One world.org

www.derekprince.co.nz PC15